**AUSTRALIAN EMBASSY**
**PHNOM PENH**

សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១

# បុរសជនជាតិអូស្ត្រាលីត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ពាក់ព័ន្ធការរំលោភបំពានផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា

បុរសជនជាតិអូស្ត្រាលីម្នាក់ ដែលបានរំលោភបំពានផ្លូវភេទលើកុមារីមួយចំនួននៅក្នុងប្រទេសកម្ពុជា ព្រមទាំងបានរក្សាទុករូបភាពរំលោភបំពានកុមារមួយចំនួន ត្រូវបានតុលាការនៅ South Australian Adelaide District Court ធ្វើការផ្តន្ទាទោសនៅថ្ងៃសុក្រ ទី១៧ ខែកញ្ញា ឆ្នាំ២០២១ អោយជាប់ពន្ធនាគាររយៈពេល០៩ឆ្នាំ និង០៦ខែ។

បុរសជនជាតិអូស្ត្រាលីដែលមានអាយុ៤៧ឆ្នាំរូបនេះ បានសារភាពកំហុសរបស់ខ្លួនកាលពីឆ្នាំមុន (ឆ្នាំ២០២០) ពាក់ព័ន្ធបទល្មើសដែលខ្លួនបានប្រព្រឹត្តចំនួន១២ករណី
ក្រោយមានការស៊ើបអង្កេតយ៉ាងយកចិត្តទុកដាក់ពីក្រុមចម្រុះប្រឆាំងការធ្វើកេងប្រវ័ញ្ចលើកុមារនៅអូស្ត្រាលីភាគខាងត្បូង (South Australia Joint Anti Child Exploitation Team-SA JACET)។
មន្ត្រីនៃក្រុមចម្រុះប្រឆាំងការធ្វើកេងប្រវ័ញ្ចលើកុមារនៅអូស្ត្រាលីភាគខាងត្បូង ដែលរួមមាននគរបាលសហព័ន្ធអូស្ត្រាលី (Australian Federal Police - AFP) និងនគរបាលប្រចាំអូស្ត្រាលីភាគខាងត្បូង (South Australia Police)
បានធ្វើការចាប់ខ្លួនបុរសជនជាតិអូស្ត្រាលីនោះកាលពីខែឧសភា ឆ្នាំ២០១៩។

ក្រុមចម្រុះប្រឆាំងការកេងប្រវ័ញ្ចលើកុមារនៅអូស្ត្រាលីភាគខាងត្បូង និងមន្ត្រីសម្របសម្រួលនគរបាលសហព័ន្ធអូស្ត្រាលី បានធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា ដើម្បីប្រមូលភស្តុតាងដាក់បន្ទុក សម្រាប់ធ្វើការផ្តន្ទាទោសដល់ជនល្មើស។ មន្ត្រីនគរបាលសហព័ន្ធអូស្ត្រាលី ប្រចាំប្រទេសកម្ពុជាជាច្រើនរូប
បានទទួលការគាំទ្រយ៉ាងច្រើនពីសំណាក់នគរបាលជាតិកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន
ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ ព្រមទាំងការផ្តល់សេវាគាំទ្រសុខុមាលភាព និងតំណាងផ្នែកច្បាប់ផងដែរ។

អង្គការក្រៅរដ្ឋាភិបាល ដែលបានជួយគាំទ្រដល់ដំណើរការនេះ រួមមានអង្គការអេផលកម្ពុជា (APLE Cambodia)
ដែលការងាររបស់ខ្លួនផ្តោតលើការការពារកុមារពីការរំលោភបំពានផ្លូវភេទ និងពីការធ្វើកេងប្រវ័ញ្ចផ្លូវភេទ
ព្រមទាំងអង្គការ Legal Impact Hub ដែលមានការអនុវត្តគំរោងនៅក្នុងប្រទេសកម្ពុជាដោយ Armin Law and Remedy Project។ The Hub គឺជាសម្ព័ន្ធភាពនៃមេធាវី និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការរួមគ្នាជាប្រព័ន្ធ
ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា។

ឯកឧត្តម ឯកអគ្គរាជទូតអូស្ត្រាលី Pablo Kang បានមានប្រសាសន៍ថា “ខ្ញុំសូមផ្តល់ការវាយតម្លៃខ្ពស់
ចំពោះកិច្ចសហប្រតិបត្តិការដ៏មានសារៈសំខាន់រវាងមន្ត្រីអនុវត្តន៍ច្បាប់អូស្ត្រាលី និងមន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា
ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលនានា ដែលបាននាំមកនូវសមិទ្ធផលនេះ”។ ឯកឧត្តម បានមានប្រសាសន៍បន្ថែមទៀតថា
“កិច្ចខិតខំប្រឹងប្រែងឥតស្រាកស្រាន្តរបស់មន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ បានបញ្ជូនសារដ៏ច្បាស់លាស់ថាអូស្ត្រាលីមិនអត់ឱនជាដាច់ខាតនូវរាល់ការរំលោភបំពានលើកុមារគ្រប់ទម្រង់។ ដើម្បីការពារដល់កុមារ
មន្ត្រីអនុវត្តច្បាប់នឹងមិនបញ្ឈប់សកម្មភាពស្រាវជ្រាវស៊ើបអង្កេតរបស់ខ្លួននោះទេ
ដរាបណាជនល្មើសពុំទាន់ត្រូវបានយកមកផ្តន្ទាទោស។”

ចំពោះសាធារណជនដែលមានមានបំណងផ្តល់ព័ត៌មានអំពីករណីរំលោភបំពាន
រឺការកេងប្រវ័ញ្ចលើកុមារដោយប្រការណាមួយ សូមធ្វើការទំនាក់ទំនងទៅកាន់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស
និងការពារអនីតិជនរបស់នគរបាលជាតិ តាមទូរស័ព្ទហតឡាញលេខ ១២៨៨ (Hotline 1288)។

ប្រសិនបើលោកអ្នកផ្ទាល់ រឺមនុស្សផ្សេងទៀតដែលលោកស្គាល់ កំពុងទទួលរងនូវផលប៉ះពាល់ពីការរំលោភបំពានផ្លូវភេទ
និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ សូមធ្វើការទំនាក់ទំនងទៅកាន់អាស័យដ្ឋាន

វេបសាយខាងក្រោមដើម្បីទទួលបាននូវសេវាគាំទ្រផ្សេងៗនៅក្នុងប្រទេសកម្ពុជា https://aplecambodia.org/wp-content/uploads/2021/08/APLE_Referral-Directory_Final_for-Web.pdf

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់៖ Australian.Embassy.Cambodia@dfat.gov.au